# ទស្សនវិជ្ជាខ្មែរអំពី កាល

## ( Khmer Philosophy of Time )

*ដោយៈ* **បណ្ឌិត ប៉ាន់ ខុន្ថា**

*មន្ត្រីស្រាវជ្រាវនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា*

*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

### សេចក្តីផ្តើម

*វត្តមាន កាល(ពេលវេលា) មានពាក់ព័ន្ធគ្រប់ផ្នែក គ្រប់វិស័យ គ្រប់សកម្មភាព និងមានសារៈសំខាន់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ។ ពេលវេលាដើរតួនាទីសំខាន់ក្នុងការកត់ត្រា ឬកំណត់កាលបរិច្ឆេទព្រឹត្តិការណ៍ និងមានបង្កប់នូវអត្ថន័យទស្សនវិជ្ជាយ៉ាងជ្រាលជ្រៅផងដែរ។ ខ្មែរយើងប្រើទាំងសុរិយគតិ ទាំងចន្ទគតិក្នុងការរាប់ ថ្ងៃ ខែ ឆ្នាំ។*

### ១-ថ្ងៃ ខែ ឆ្នាំ និង រដូវ តាមចន្ទគតិ

#### ក-ថ្ងៃ

*ក្នុងការកំណត់ឈ្មោះថ្ងៃ គឺបុព្វបុរសខ្មែរយកតាមឈ្មោះផ្កាយព្រះគ្រោះទាំង៧ ៖ ព្រះអាទិត្យ ព្រះចន្ទ ព្រះអង្គារ ព្រះពុធ ព្រះហស្បតិ៍ ព្រះសុក្រ ព្រះសៅរ៍។ បើតំណាងជា លេខ គឺគេយកថ្ងៃអាទិត្យជាថ្ងៃទី១ ចន្ទទី២ តរៀងទៅ។ បុព្វបុរសខ្មែរក៏បានកំណត់ថ្ងៃតំណាងដោយសត្វ៧ប្រភេទដែរគឺ ៖ អាទិត្យក្តាន់ ច័ន្ទខ្លា អង្គារខ្វែង ពុធអក ព្រហស្បតិ៍កុក សុក្រតោរ៉ៅ សៅរ៍ទីទុយ។ ក្នុងមួយសប្តាហ៍មាន៧ថ្ងៃនេះ មានថ្ងៃលិច ថ្ងៃអណ្តែត មានថ្ងៃកាចថ្ងៃជា។*

#### ខ-ខែ

*ខែតាមចន្ទគតិមាន១២គឺ ៖ មគិសិរ បុស្ស មាឃ ផល្គុន ចេត្រ ពិសាខ ជេស្ឋ អាសាឍ ស្រាពណ៍ ភទ្របទ អស្សុជ កត្តិក។ បុព្វបុរសខ្មែរមានការបែងចែកខែខាងខ្នើត ខែខាងរនោច និងខែញី ខែឈ្មោល។*

ខែតាមចន្ទគតិមាន៣០ថ្ងៃ ហៅថា ខែញី ហើយខែតាមចន្ទគតិមាន២៩ថ្ងៃ ហៅថា ខែឈ្មោល។ បើកំណត់ជាលេខ គេរាប់ខែមគិសិរ(ខែញី) ជាខែទី១ បុស្សជាខែទី២ (ខែឈ្មោល) តរៀងទៅ។ ក្នុងគំនិតខ្មែរ ខែ មានន័យថា ព្រះខែ ឬ ព្រះចន្ទ។ ខែ ក៏មានន័យថា ជាខួប ហើយក៏មានន័យថា រដូវដែរ ដូចជា ខែត្រីពង ខែស្វាយ ខែមៀន ខែច្រូត... ជាដើម។ ក្នុង១២ខែនេះ មានខែលិច ខែអណ្តែត។

**គ-ឆ្នាំ**

បុព្វបុរសខ្មែរបានប្រើប្រាស់ឆ្នាំភ្ជាប់ទៅនឹងសត្វ១២ប្រភេទគឺ ៖ ជូត(កណ្តុរ) ឆ្លូវ(គោ) ខាល(ខ្លា) ថោះ(ទន្សាយ) រោង(នាគ) ម្សាញ់(ពស់) មមី(សេះ) មមែ(ពពែ) វក(ស្វា) រកា(មាន់) ច(ឆ្កែ) កោ(ជ្រូក)។ បើរាប់ជាលេខ គេយកឆ្នាំជូត ជា ឆ្នាំទី១ ឆ្លូវទី២ តរៀង។

**ឃ-រដូវ**

រដូវ មាន២គឺ រដូវប្រាំង និងរដូវវស្សា ហើយមានសារៈសំខាន់ក្នុងជីវភាពរស់នៅ។ រដូវទាំង២នេះបានចែកស្ថានភាពរស់នៅ អាកប្បកិរិយា ទម្លាប់ និងការប្រកបការងារចិញ្ចឹមជីវិតរបស់ប្រជាជនខ្មែរខុសគ្នាគឺ ៦ខែជារដូវវស្សា ជាពេលប្រកបរបររកស៊ី ធ្វើស្រែ ធ្វើចំការ និង៦ខែទៀតជារដូវប្រាំង ជាពេលដែលប្រជាជនទំនេររួចពីការងារស្រែចំការ ហើយពេលនេះជាពេលគេសប្បាយរីករាយ និងធ្វើបុណ្យធ្វើទានរៀបមង្គលការ ប្រារព្ធពិធីផ្សេងៗ និងរាំច្រៀងសប្បាយស្មើរពេញមួយរដូវ។ រដូវជារដ្ឋនៃពេល ដោយគេសម្គាល់រាល់របស់ដែលមានក្នុងធម្មជាតិ និងទង្វើរបស់មនុស្ស ហើយដែលមានភាពទៀងទាត់ ដូចជា រដូវស្វាយទុំ រដូវច្រូតកាត់ រដូវរងារ រដូវទឹកឡើង រដូវទឹកស្រក រដូវក្តៅ រដូវកឋិន រដូវចូលឆ្នាំ ជាដើម។

## ២-ការជ្រើសរើសពេលា

ក្នុងផ្នត់គំនិតខ្មែរ **ថ្ងៃ ខែ ឆ្នាំ រដូវ** ដើរតួនាទីយ៉ាងសំខាន់សម្រាប់គុណគូរនូវរាល់ការទស្សន៍ទាយមើលពីពេលា ជោគជតារាសី ការផ្សំផ្គុំគូរស្រករ ទស្សន៍ទាយមើលហេតុភេទដែលអាចនឹងកើតមានក្នុងការធ្វើដំណើរ និងក្នុងការប្រកបកិច្ចការអ្វីមួយ ការទស្សទាយពីជំងឺព្យាបាលបានឬមិនបាន និងការកំណត់ថ្ងៃអង្គារបស់មនុស្សម្នាក់ៗផងដែរ។

**ក-ពេលាអខ្សារ**

តាមក្បួនព្រាហ្មណ៍ ពាក្យហៅថ្ងៃទាំង៧ តាំងពីថ្ងៃអាទិត្យដល់ថ្ងៃសៅរ៍ ដែលតម្រូវនឹងឆ្នាំកំណើតតាមជតារបស់មនុស្ស ហៅថា អង្សាកំណើត គឺតម្រូវដោយកំណត់ថា ៖ ឆ្នាំជូតនិងឆ្នាំមមែអង្សាអាទិត្យ ឆ្នាំឆ្លូវនិងឆ្នាំវកអង្សាចន្ទ ឆ្នាំខាលនិងឆ្នាំរកាអង្សាអង្គារ ឆ្នាំថោះនិងឆ្នាំចអង្សាពុធ ឆ្នាំរោងនិងឆ្នាំកុរអង្សាព្រហស្បតិ៍ ឆ្នាំម្សាញ់អង្សាសុក្រ ឆ្នាំមមីអង្សាសៅរ៍។ តាមការកត់ចំណាំ មនុស្សចាស់ជរា វេលានឹងស្លាប់ច្រើនតែស្លាប់ក្នុងថ្ងៃអង្សារបស់ខ្លួនឬក្នុងថ្ងៃដើមអង្សា(មុនថ្ងៃអង្សា១ថ្ងៃ)ឬក្នុងថ្ងៃចុងអង្សា(ក្រោយថ្ងៃអង្សា១ថ្ងៃ) មិនសូវលើសខ្វះឆ្ងាយពីនេះប៉ុន្មានទេ។

**ខ-ពេលាលិច ពេលាអណ្ដែត ឬ ពេលាភាច ពេលាជា**

ក្នុងការរស់នៅប្រចាំថ្ងៃ ជតារាសីជីវិតរបស់គេជួបរឿងល្អឬអាក្រក់ គឺអាស្រ័យទៅនឹងទីតាំងក្រុមផ្កាយទាំង៩គិតធៀបមកលើផែនដី។ ខ្មែរមានជំនឿលើ ឆ្នាំ ខែ ថ្ងៃ អណ្ដែត និង ឆ្នាំ ខែ ថ្ងៃ លិច ដែលជាពេលាល្អណាស់ ឬ ពេលាល្អល្មម ឬ ពេលាអាក្រក់ ហើយគេជ្រើសរើសយកតែ ឆ្នាំ ខែ ថ្ងៃ ដែលជាពេលាមង្គល ជាពេលាល្អណាស់ ឬ ពេលាល្អល្មម សម្រាប់រៀបចំពិធីសំខាន់ៗ សម្រាប់ខ្លួនធ្វើអ្វីៗក្នុងជីវិត និងដើម្បីប្រារព្ធពិធីផ្សេងៗក្នុងសាសនា ដើម្បីឱ្យមានសិរីសួស្ដី ជៀសវាងការខាតបង់ និងមានគ្រោះថ្នាក់ៗ រីឯ ឆ្នាំ ខែ ថ្ងៃ ដែលជា ពេលាអាក្រក់ គេមិនហ៊ានធ្វើពិធី និងសម្រេចធ្វើកិច្ចការអ្វីទេ ព្រោះគេបារម្ភណ៍ខ្លាចជួបគ្រោះថ្នាក់ឬខាតបង់ទ្រព្យសម្បត្តិ។ ដោយសារតែសារៈសំខាន់នៃពេលវេលានេះហើយ ដែលអាចធ្វើឱ្យខកខានក្នុងការប្រារព្ធពិធីក៏មាន ព្រោះតែរើសពេលាមិនបាន ឬពេលដែលត្រូវធ្វើនោះកន្លងផុតទៅដោយគេមិនអាច រកថ្ងៃថ្មីមកជំនួស ដូចនេះ គេត្រូវរង់ចាំ ខែ ថ្ងៃ ដែលជាពេលាល្អនៅពេលក្រោយ។

ក្នុងការរាប់ ឆ្នាំ ខែ ថ្ងៃ លិច និង ឆ្នាំ ខែ ថ្ងៃ អណ្ដែត គោងរាប់ទៅតាមឆ្នាំសត្វទាំង១២ ហើយការរាប់គុណគូររកនេះគឺអាស្រ័យទាំងស្រុងលើអាចារ្យ និងគ្រូហោរ។ នេះជាគំរូឧទាហរណ៍ខ្លះៗនៃការជ្រើសរើស ឆ្នាំ ខែ ថ្ងៃ ល្អ មាននក្ខតឫក្ស ដើម្បីធ្វើពិធីបុណ្យ ចាប់ផ្ដើមប្រកបមុខរបរ សាង

សង់លំនៅឋាន ទិញលក់ទំនិញ ចូលនៅផ្ទះថ្មី កប់ឬបូជាសព ជាដើម ៖

***ខ-១-១***-ឆ្នាំជូត ខែពិសាខ ថ្ងៃអាទិត្យជា ពេលាអាក្រក់។

-ឆ្នាំជូត ខែជេស្ឋ ថ្ងៃសៅរ៍ជា ពេលាល្អល្មម

-ឆ្នាំជូត ខែអាសាឍ ថ្ងៃសុក្រជា ពេលាល្អណាស់

***ខ-១-២***-ឆ្នាំឆ្លូវ ខែជេស្ឋ ថ្ងៃចន្ទជា ពេលាអាក្រក់

-ឆ្នាំឆ្លូវ ខែជេស្ឋ ថ្ងៃសៅរ៍ជា ពេលាល្អល្មម

-ឆ្នាំឆ្លូវ ខែស្រាពណ៍ ថ្ងៃព្រហស្បតិ៍ជា ពេលាល្អណាស់

***ខ-១-៣***-ឆ្នាំខាល ខែអាសាឍ ថ្ងៃអង្គារជា ពេលាអាក្រក់

-ឆ្នាំខាល ខែស្រាពណ៍ ថ្ងៃចន្ទជា ពេលាល្អល្មម

-ឆ្នាំខាល ខែភទ្របទ ថ្ងៃអាទិត្យជា ពេលាល្អណាស់។

បើគេប្រារព្ធពិធីតាមពេលាល្អណាស់ នោះនឹងនាំមកនូវសិរីសួស្តី ជ័យមង្គល និងវិបុលភាព។

នៅតំបន់ខ្លះ គេមិនជ្រើសយកថ្ងៃលិច ថ្ងៃអណ្តែតទេ តែគេជ្រើសយក ថ្ងៃកាច ថ្ងៃជា មកគុណគួរសម្រាប់ជ្រើសរើសពេលាមង្គល ដើម្បីប្រារព្ធពិធីមង្គលអាពាហ៍ពិពាហ៍ និងពិធីបុណ្យផ្សេងៗ ហើយការរើសនោះគេមិនយកថ្ងៃកាច ព្រោះតែក្នុងគំនិតរបស់ប្រជាជនខ្មែរយល់ថា រាល់ពិធីធ្វើនៅថ្ងៃកាចទាំងអស់គឺមិនបាននូវសុកមង្គល និងសិរីសួស្តីដល់ម្ចាស់ដើមមង្គលការ ឬដើមបុណ្យទេ។ នេះជាគំរូឧទាហរណ៍ខ្លះៗនៃ ថ្ងៃកាច និង ថ្ងៃជា តាមខែនិមួយៗ និងក្នុងសប្តាហ៍ ៖

***ខ-២-១***-ថ្ងៃកាច ក្នុងខែនីមួយៗ ៖

-ខែផល្គុន និងខែចេត្រ ៩កើត និង ៩រោច ជាថ្ងៃកាច

-ខែពិសាខ និងខែជេស្ឋ ៦កើត និង៦រោច ជាថ្ងៃកាច

-ខែអាសាឍ និងខែស្រាពណ៍ ១កើត និង១រោច ជាថ្ងៃកាច

***ខ-២-២***-ថ្ងៃកាច ក្នុងសប្តាហ៍ ៖

-ថ្ងៃអាទិត្យ ១២កើត និង១២រោច ជា ថ្ងៃកាច

-ថ្ងៃចន្ទ ១១កើត និង១១រោច ជា ថ្ងៃកាច

ថ្ងៃអង្គារ ១០កើត និង១០រោច ជា ថ្ងៃកាច

- ថ្ងៃជា ក្នុងសប្តាហ៍ ៖

ថ្ងៃអាទិត្យ ៨កើត និង៨រោច ជា ថ្ងៃជា

ថ្ងៃចន្ទ ៣កើត និង៣រោច ជា ថ្ងៃជា

ថ្ងៃអង្គារ ៧កើត និង៧រោច ជា ថ្ងៃជា។

ការជ្រើសរើសបាន ឆ្នាំ ខែ ថ្ងៃ ល្អ មាននក្ខត្តឫក្ស ធ្វើឱ្យគេមានទំនុកចិត្ត និងមានអារម្មណ៍ជឿជាក់ថា រៀបចំពិធីរួចហើយ នឹងនាំមកនូវសិរីសួស្តី ជ័យមង្គល លាភសំណាង វិបុលភាព អាយុយឺនយូរ មកដល់ពួកគេជាក់ជាមិនខាន។

**គ-ការជ្រើសរើសពេលកាប់ឈើធ្វើផ្ទះ ធ្វើនង្គ័ល ធ្វើរនាស់**

ក្នុងផ្នត់គំនិតខ្មែរ ត្រូវមានធ្វើពិធីបួងសួងសុំម្ចាស់ទឹក ម្ចាស់ដី ម្ចាស់ព្រៃ និងកាន់ត្រណមជាច្រើន ដើម្បីកុំឱ្យសត្វសាហាវបៀតបៀន និងវង្វេងផ្លូវ ហើយការជ្រើសពេលល្អចេញទៅព្រៃ គឺត្រូវទៅនៅថ្ងៃ៣ (ថ្ងៃអង្គារ) បើចេញទៅកាប់ឈើធ្វើធ្យូងត្រូវចេញទៅនៅថ្ងៃ១(ថ្ងៃអាទិត្យ) ទើបទទួលបានផលល្អ និងមានសេចក្តីសុខ។

**ឃ-ការជ្រើសរើសពេលល្អក្នុងការដាំដំណាំ និងប្រមូលផល**

ក្នុងផ្នត់គំនិតខ្មែរ មានជំនឿថា៖ ការដាំដំណាំសព្វសារពើ បើដាំនៅថ្ងៃ១ (ថ្ងៃអាទិត្យ)នឹងបានផលទ្វេជា៤។ បើដាំនៅថ្ងៃ២(ចន្ទ)ពុំសូវល្អ។ បើដាំនៅថ្ងៃ៣ (ថ្ងៃអង្គារ) នឹងបានផលទ្វេជា២។ បើដាំនៅថ្ងៃ៤ (ថ្ងៃពុធ)នឹងខាត។ បើដាំនៅថ្ងៃ៥ (ថ្ងៃព្រហស្បតិ៍) ដំណាំពុំសូវល្អ។ បើដាំនៅថ្ងៃ៦ (ថ្ងៃសុក្រ)នឹងបានផលទ្វេជា៥។ បើដាំនៅថ្ងៃ៧ (ថ្ងៃសៅរ៍)នឹងពុំបានផលស្មើពូជមកវិញទេ។ បើសាបស្រូវ ត្រូវសាបថ្ងៃ៦ (ថ្ងៃសុក្រ)។ បើច្រូតស្រូវត្រូវច្រូតថ្ងៃ៧ (ថ្ងៃសៅរ៍) រៀបកណ្តាប់បែនថ្ងៃ៤(ថ្ងៃពុធ) ហើយយកស្រូវឡើងផ្ទះថ្ងៃ២ ឬថ្ងៃ៣ ឬថ្ងៃ៦ ព្រោះថ្ងៃទាំងអស់នេះសុទ្ធតែជាថ្ងៃជា។ ថ្ងៃ២កើត ថ្ងៃ៧កើត និងថ្ងៃ៧រោច ថ្ងៃទាំង៣នេះរាល់ខែប៉ះចំថ្ងៃខ្មោចស៊ីស្រូវ គេមិនដឹកយកស្រូវទៅដាក់ជង្រុកទេ ព្រោះជាថ្ងៃកាច ជាថ្ងៃអន្តរាយ។

**ង-ការជ្រើសពេលសង់ផ្ទះ លើកផ្ទះ និងឡើងផ្ទះ**

ក្នុងផ្នត់គំនិតខ្មែរតែងតែឱ្យហោរាគុណាគូរជ្រើសយកខែអណ្តែត ថ្ងៃអណ្តែត ដើម្បីឱ្យការរស់នៅរបស់ពួកគេក្នុងផ្ទះនោះមាន

សេចក្ដីសុខ សុភមង្គល និងប្រកបរបរកបប្រសើរ។

**ច-ការជ្រើសពេលាទិញរបស់អ្វីមួយចូលផ្ទះ**

ក្នុងផ្នត់គំនិតខ្មែរ ការជ្រើសពេលាទិញរបស់អ្វីមួយចូលផ្ទះ ដូចជា គោ ក្របី ជ្រូក យានជំនិះ នង្គ័ល រនាស់ និងយកខ្ញុំបម្រើចូលផ្ទះ ជាដើម គេជៀសវាងថ្ងៃលិចថ្ងៃកាច ថ្ងៃខ្មោចស៊ី។

**ឆ-ការជ្រើសពេលាធ្វើដំណើរ**

ក្នុងផ្នត់គំនិតខ្មែរ គេអាចជ្រើសយកតាមជីបចរ ឬគេអាចជ្រើសយកតាមថ្ងៃអង្គារ ឬគេអាចជ្រើសយកតាមយាមខុនរង (ឬទៅតាមទិសនៃដង្ហើមរស់)។ ជួនកាលការធ្វើដំណើរទៅណាមកណា គេនិយមធ្វើដំណើរនៅពេលព្រលឹម ដែលជាពេលត្រជាក់ត្រជុំ ហើយគេមិនឱ្យធ្វើដំណើរទៅណាមកណាចំពេលថ្ងៃត្រង់ (ម៉ោង១២ថ្ងៃត្រង់) ទេ ដោយគេមានជំនឿថា ជាពេលខ្មោចចេញដើរ នឹងនាំឱ្យមានប៉ះពាល់ដល់ខ្មោច ជាប្រការមិនល្អ។

**ជ-ការជ្រើសពេលាកប់សុក**

ក្នុងផ្នត់គំនិតខ្មែរ កាលណាស្ត្រីបានឆ្លងទន្លេផ្ដល់កំណើតដល់ទារកហើយនោះសមាជិកគ្រួសារនឹងយកសុកទៅកប់នៅ២ ឬ៣ថ្ងៃបន្ទាប់ ឬក្រោយពិធីទម្លាក់ចង្ក្រាន ក្នុងគោលបំណងឱ្យមានសិរីសួស្ដីដល់ទារក។ ក្នុងការកប់សុកនេះ គេជ្រើសពេលា (កាល) និងទិសនៃលំហ ដូចតទៅ ៖

-បើកប់សុកនៅខែចេត្រ ខែពិសាខ និងខែផល្គុន មិនឱ្យកប់នៅទិសខាងកើតទេ នោះកូននឹងស្លាប់ពីក្មេង។ឱ្យកប់នៅទិសឥសាន ទិសអគ្នេយ៍នឹងបានក្លាយជាអ្នកប្រាជ្ញ។

-បើកប់សុកនៅខែជេស្ឋ ខែអាសាឍ និងខែស្រាពណ៍ មិនឱ្យកប់នៅទិសបច្ចិមទេ នោះកូននឹងស្លាប់ពីក្មេង។ ឱ្យកប់នៅទិសឥសាន នៅដល់ទុំស្លាប់ ឱ្យកប់នៅទិសឧត្តរ នឹងបានក្លាយជាអ្នកប្រាជ្ញ និងមានអាយុយឺនយូរ។

-បើកប់សុកនៅខែភទ្របទ ខែអស្សុជ និងខែកត្តិក មិនឱ្យកប់នៅទិសឧត្តរទេ ទារកនឹងស្លាប់។ ឱ្យកប់នៅទិសឥសាន នឹងបានក្លាយជាអ្នកប្រាជ្ញ។

**ឈ-ការជ្រើសពេលារៀបមង្គលការកូនចៅ**

ការរៀបចំមង្គលការកូនចៅសម្រាប់ប្រជាជនខ្មែរជាបញ្ហាសំខាន់ ហេតុនេះការរៀបចំពិធីមង្គលការត្រូវតែធ្វើទៅតាមក្បួន

ខ្នាតឱ្យបានត្រឹមត្រូវ និងជ្រើសរើសពេលាល្អ។ ការធ្វើតាមក្បួនខ្នាតគឺគ្រូហោរឬអាចារ្យត្រូវវាយលេខអត្តៈគុណគូរ ការផ្សំពង្ស ការផ្សំធាតុ ការផ្សំឆ្នាំសត្វ ការផ្សំថ្ងៃខែឆ្នាំកំណើត ការផ្សំសម្បត្តិ ផ្សំឈ្មោះនិងនាមភូមិឋាន ជ្រើសពេលាល្អរៀបចំមង្គលឱ្យត្រូវខែអណ្ដែត ថ្ងៃអណ្ដែតឬថ្ងៃជា និងផ្ទៀងផ្ទាត់តាមក្បួនហោរា រកថ្ងៃជាពេលាល្អទាំងថ្ងៃចូលរោង(យកពេលាល្អល្មម) ទាំងថ្ងៃរៀបការ(យកថ្ងៃជាពេលាល្អ) ជាពិសេសគឺ ពេលារួមខ្នើយ សម្រាប់គូស្វាមីភរិយាថ្មីឱ្យសមប្រកប និងមានសិរីសួស្ដីជ័យមង្គលវិបុលភាពក្នុងជីវិត ដែលជាបំណងរបស់ប្រជាជនខ្មែរត្រូវការ។ ពេលារួមខ្នើយ គឺ ពេលាសំពះផ្ទឹម គឺគេត្រូវជ្រើសយកពេលសិរីមង្គល ជាថ្ងៃដែលដំណេកអ្នកទាំង២រួមគ្នាលើខ្នើយតែមួយ។ បើការនៅខាងខ្នើត ឱ្យយកថ្ងៃ ៥កើត ៦កើត ៧កើត ១០កើត និង១៣កើត។ បើការនៅខាងរនោច ឱ្យយកថ្ងៃ ២រោច ៤រោច ៦រោច ៨រោច ១០រោច ១១រោច ១៤រោច។ ការរើសនេះមិនប្រកាន់ខែណាៗនោះទេ ហើយពេលាផ្ទឹមគឺ ៖

-បើការថ្ងៃអាទិត្យ បាននៅម៉ោង១ ម៉ោង៣ ម៉ោង៨ ម៉ោង១០។

-បើការថ្ងៃចន្ទ បាននៅម៉ោង២ ម៉ោង៤ ម៉ោង៩ ម៉ោង១០។

-បើការថ្ងៃអង្គារ បាននៅម៉ោង១ ម៉ោង៣ ម៉ោង៥ ម៉ោង៨ ម៉ោង១០ ម៉ោង១២។ ល។

ក្បួននេះបានបញ្ជាក់ថា ក្រៅពីម៉ោងខាងលើ គឺមិនអាចសំពះផ្ទឹមបានទេ។

ប៉ុន្តែ ពិធីមង្គលការបច្ចុប្បន្ន មិនគោរពតាមបទដ្ឋានក្បួនខ្នាតនេះទេ ដោយគេចាប់ផ្ដើមពិធីនៅពេលព្រលឹម ដែលពួកគេមានទស្សនៈយល់ថា ជាពេលដែលត្រជាក់ត្រជុំ ដល់គូស្វាម៉ីភរិយាថ្មី ហើយតែងតែបញ្ចប់មុនពេលថ្ងៃត្រង់ (មុនពេលខ្មោចចេញដើរ) នឹងមានសិរីសួស្ដីដល់គូស្វាម៉ីភរិយាថ្មី។ កាលដែលពេលវេលា មានសារៈសំខាន់សម្រាប់ពីធីមង្គលការនេះហើយ ទើបជារឿយៗ យើងឮគេស្រែកក្នុងពិធីថា ថ្ងៃនេះថ្ងៃជាពេលាល្អ ថ្ងៃនេះថ្ងៃជាពេលាបាន ស្ទើរតែគ្រប់ពេល។

### ញ-ការជ្រើសពេលានៅយកគ្រូជាតិមកធ្វើថ្នាំព្យាបាលជំងឺ

ក្នុងការព្យាបាលជំងឺ មានទាក់ទងចាំបាច់ជាមួយ ថ្ងៃ ខែ ឆ្នាំ (ពេលវេលា)

កំណើត ពិតប្រាកដរបស់អ្នកជំងឺ ដើម្បីធ្វើពិធីព្យាបាលទៅតាមក្បួនខ្នាត។ ក្នុងផ្នត់គំនិតខ្មែរ មានជំនឿថា ពេលវេលា មានទំនាក់ទំនងនឹងទីតាំងស្តេចថ្នាំ តាំងនៅលើដើមថ្នាំរុក្ខជាតិនោះ៖

-ថ្ងៃ១ ព្រឹកស្តេចថ្នាំនៅដើម ពេញពន្លឺស្តេចថ្នាំនៅសព្វកន្ទែងនៃដើមទាំងមូល ថ្ងៃត្រង់ស្តេចថ្នាំនៅស្លឹក ពេលល្ងាចស្តេចថ្នាំនៅសំបក។

-ថ្ងៃ២ ព្រឹកស្តេចថ្នាំនៅឫស ពេញពន្លឺស្តេចថ្នាំនៅខ្លឹម ថ្ងៃត្រង់ស្តេចថ្នាំនៅស្លឹក ពេលសុរិយាអស្តង្គតស្តេចថ្នាំនៅសំបក។

-ថ្ងៃ៣ ព្រឹកស្តេចថ្នាំនៅឫស ពេញពន្លឺស្តេចថ្នាំនៅសំបក ថ្ងៃត្រង់ស្តេចថ្នាំនៅដើម ពេលសុរិយាអស្តង្គតស្តេចថ្នាំនៅឫស។

-ថ្ងៃ៤ ព្រឹកស្តេចថ្នាំនៅឫស ពេញពន្លឺស្តេចថ្នាំនៅឫស ថ្ងៃត្រង់ស្តេចថ្នាំនៅ សំបក ពេលល្ងាចស្តេចថ្នាំនៅខ្លឹម។

-ថ្ងៃ៥ ព្រឹកស្តេចថ្នាំនៅដើម ពេញពន្លឺស្តេចថ្នាំនៅសព្វកន្ទែងនៃដើមទាំងមូល ថ្ងៃត្រង់ស្តេចថ្នាំនៅស្លឹក ពេលល្ងាចស្តេចថ្នាំនៅសំបក។

-រីឯថ្ងៃ៦ ថ្ងៃ៧ កុំទៅយកថ្នាំ ព្រោះតែជាតុថ្នាំស្រូបចុះទៅក្រោមផុតពីដើមអស់។

## ៣ - ពេលវេលាជាអាទិទេព

ក្រៅពីមានទស្សនៈអំពី ពេលាល្អ ពេលាអាក្រក់ ពេលាលិច ពេលាអណ្តែត ពេលាកាច ពេលាជា ក្នុងទស្សនៈខ្មែរក៏បានចាត់ទុក កាល ជា អាទិទេព ផងដែរ។ កាល ឬពេល (សំស្ក្រឹត) មានន័យថា ទីបញ្ចប់ ឬសេចក្តីស្លាប់។ ដោយសារតែខ្មែរយល់ពីពេលវេលា ថា មូល ដូចនេះហើយ ដែលធ្វើឱ្យពេលកើត និងពេលស្លាប់ស្ថិតនៅជិតគ្នា។ ការដែលយល់បែបនេះហើយ ទើបខ្មែរប្រើពាក្យសម្គាល់សេចក្តីស្លាប់គឺ មរណៈកាល ដល់កាល ... ក្នុងពាក្យទាំងនេះវត្តមាននៃ កាល មានន័យថា បញ្ចប់ ឬ សេចក្តីស្លាប់។ ក្នុងទស្សនៈខ្មែរ ចាត់ទុក កាល ជា ព្រះ គឺ ព្រះកាល។ ព្រះកាល និង ព្រះយមរាជ ជាទេពនៃសេចក្តីស្លាប់។ ព្រះកាល និង ព្រះយមរាជ ខ្មែរតែងបង្ហាញរូបចម្លាក់ជាមនុស្សកាន់ដំបង។ ប៉ុន្តែ ខណៈខ្លះ ខ្មែរសំយោគព្រះទាំង២អង្គនេះចូលគ្នា ហើយហៅឈ្មោះថា ព្រះកាលយមរាជ ហើយតែងបង្ហាញរូបចម្លាក់ជាមនុស្សមានក្បាល

ដុះស្នែងក្របី ខណៈខ្លះទៀត ខ្មែរបង្ហាញរូបព្រះកាល ក្នុងភាពជាមនុស្សមានតែក្បាលនិងដៃដែលចាប់លេបព្រះអាទិត្យ ឬព្រះចន្ទ ដែលខ្មែរនិយមហៅថា រាហ៊ូ។ ព្រះអាទិត្យ និងព្រះចន្ទ ជាទេពនៃពេលវេលាកាលដែលរាហ៊ូលេបពេល ដូចធ្វើឱ្យបាត់ពេល គឺស្មើនឹងសេចក្តីស្លាប់។ ដោយសាររាហ៊ូ តំណាងសេចក្តីស្លាប់នេះហើយ ទើបខ្មែរគូរឬឆ្លាក់រូប រាហ៊ូ នៅលើមឈូស មេរុបច្ឆា ... ដែលតំណាងនូវសេចក្តីស្លាប់ ឬទីស្លាប់។ នៅក្នុងផ្នត់គំនិតខ្មែរ ក៏បានចាត់ទុករាហ៊ូ ជាទេពមួយអង្គក្នុងចំណោមទេពទាំង ៩ នៃក្រុមផ្កាយនព្វគ្រោះគឺ៖ ព្រះអាទិត្យ ព្រះចន្ទ ព្រះពុធ ព្រះអង្គារ ព្រះធរណី ព្រះហស្បតិ៍ ព្រះសុក្រ ព្រះសៅរ៍ រាហ៊ូ។ ទេពទាំងនេះមានតួនាទីខុសៗគ្នា ទៅ តាមកាលៈទេសៈ និងទៅតាមពិធីនៃជំនឿរបស់ខ្មែរ។ ប៉ុន្តែ ទេពដែលខ្មែរនិយមស្រលាញ់គោរពញឹកញាប់គឺ ៖ ព្រះអាទិត្យ ព្រះចន្ទ ព្រះធរណី និង រាហ៊ូ។ ក្រុមទេពទាំង៩នេះមានតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ជតារាសីជីវិតរបស់មនុស្ស និងធ្វើឱ្យមានការប្រែប្រួលហេតុការណ៍នៅលើផែនដីផងដែរ។

## សេចក្តីសន្និដ្ឋាន

សារុបមក យើងអាចសន្និដ្ឋានបានថា ពេលវេលា ជិតដាមជាប់ជាមួយប្រជាជនខ្មែរ ហើយកប់យ៉ាងជ្រៅនៅក្នុងផ្នត់គំនិតទស្សនវិជ្ជា និងមានទំនាក់ទំនងជា មួយសកម្មភាព ការរស់នៅ និងការកំណត់វាសនារបស់ប្រជាជនខ្មែរមិនអាចខ្វះបាន។ការយល់ដឹងពីអត្ថន័យទស្សនវិជ្ជាកាល (ពេលវេលា) ពិតជាមានសារៈសំខាន់និងអាចនាំមនុស្សទាញតម្លៃពីពេលវេលាបាន។ ក៏ប៉ុន្តែសព្វថ្ងៃ ខ្មែរហាក់ដូចជាមិនសូវយកចិត្តទុកដាក់នឹងឱ្យតម្លៃលើពេលវេលសោះ គឺគេស៊ីពេលវេលា មិនគោរពពេលវេលា។ គេមិនបានគិតថា ពេលវេលាជាមាសប្រាក់ទេ។ មានលុយ គេអាចទិញនាឡិការបាន ប៉ុន្តែគេមិនអាចទិញពេលវេលាបានទេ។

## ឯកសារពិគ្រោះ


១-ក្រាំងវត្តពោធិរតនារាម ហៅវត្តស្អាង Fonds d'Édition des Manuscrits Cambodge (FEMC) លេខ ១២១។

២-កើត ជួន ៖ ***ក្បួនទាយហេតុបណ្ដាលឱ្យឈឺនិងសែនខ្មោច*** ឯកសារក្រុមជំនុំទំនៀមទម្លាប់ ឃុំពាមឧញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្ដាល ១៩៥០។

៣-កើត ជួន ៖ ***ព្យាករណ៍តាមថ្ងៃ*** ឯកសារក្រុមជំនុំទំនៀមទម្លាប់ ឃុំពាមឧញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្ដាល ១៩៥០។

៤-ឃុនពេជ្រសុរិយា ញ៉ែម ចន ៖ ***ប្រជុំក្បួនពិភេកហោរា*** ភ្នំពេញ ១៩៩៩។

៥-អ៊ឹម បូរិន្ទ ៖ តម្រាហោរាសាស្ត្រប្រចាំគ្រួសារ ភ្នំពេញ១៩៩៩

៦-F.G. Faraut : Astronomie Combodgiene, Phnom Penh, 1910.